ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គាំពារសង្គមកម្ពុជា

SOCIAL PROTECTION IN CAMBODIA

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៥១)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៣ ៣២២ នាក់ នៃរោងចក្រ សហគ្រាស ទាំង៤១ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ៧៥០រៀល (១៥ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ៣០ថ្ងៃ
- ២៨៣ ៥០០រៀល (៧០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ៣១ថ្ងៃ ដល់ ៤៩ថ្ងៃ
- ៣២៤ ០០០រៀល (៨០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ៥០ថ្ងៃ ដល់ ៦០ថ្ងៃ

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៤១ នេះ មិនបានទទួលសារទូរសព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ព្រហស្បតិ៍ ១រោច ខែ ពិសាខ ឆ្នាំឆ្លូវ ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១

## បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ៤១ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 5 |
| 1 | ក្រុមហ៊ុន ស្កាយ ហាយ (ខេមបូឌា) ខូអិលធីឌី | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ដាប់ប៊ីលយូ អ៊ែនដ៍ ឌី កម្ពុជា | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ញូ ហូរីស អីភែរីល (ខេមបូឌា) ឯ ក | កណ្ដាល |
| 4 | ក្រុមហ៊ុន វ៉ាន់កូ អ៊ិនដាសស្ទ្រៀល ខូ អិលធីឌី | កណ្ដាល |
| 5 | ក្រុមហ៊ុន ស៊ុនជីនថេកស្កាយ(ខេមបូឌា)ខូ.,អិលធីឌី | តាកែវ |
| ខ. វិស័យទេសចរណ៍ | | 36 |
| 6 | សណ្ឋាគារ វ៉ាហ្វិល រ៉ូយ៉ាល់ | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ម៉ាស្ទ័រស៊ុគីស៊ុប | ភ្នំពេញ |
| 8 | ក្រុមហ៊ុន កាំបូឌីយ៉ាណា អ៊ិនវេស្តមេនធ៍ (ភ្នំពេញ) ភីធីអ៊ី អែលធីឌី | ភ្នំពេញ |
| 9 | ក្រុមហ៊ុន ខាល់នី ស្ប៉ាយស៍ (ខេមបូឌា) ខូអិលធីឌី | ភ្នំពេញ |
| 10 | ក្រុមហ៊ុន ដាវ៉ា អ៊ែរផត ហូថេល | ភ្នំពេញ |
| 11 | សណ្ឋាគារ ហ្គាឌិន ស៊ីធី ហូថេល | ភ្នំពេញ |
| 12 | ក្រុមហ៊ុន ស្មាយវើលដ៏ ត្រាវ៉េល &ធួរ ឯ.ក | ភ្នំពេញ |
| 13 | ក្រុមហ៊ុន វីណា ហុងកុង ខំផែនី អែលធីឌី | ភ្នំពេញ |
| 14 | ក្រុមហ៊ុន កូបេ យៃភែននីស រ៉េស្ទូរ៉េន | សៀមរាប |
| 15 | ក្រុមហ៊ុន បាហ្វឺឡូធួរ (ខេមបូឌា) លីមីតធីត | សៀមរាប |
| 16 | សណ្ឋាគារ សិន្តា មុន្នី | សៀមរាប |

| ល.រ | ឈ្មោះពេទចក្រ សហគ្រាស | រាជធានី ខេត្ត |
| --- | --- | --- |
| 17 | សណ្ឋាគារ លីនាយាអង្គរ រីសត និងស្ប៉ា | សៀមរាប |
| 18 | ក្រុមហ៊ុន ជី អេវៀរី | សៀមរាប |
| 19 | សណ្ឋាគារគូលែន | សៀមរាប |
| 20 | ក្រុមហ៊ុន អញ្ជលី បាយ ស៊ីផុន | សៀមរាប |
| 21 | អាហារដ្ឋានផ្ទះបាយខ្មែរកៀក | សៀមរាប |
| 22 | សណ្ឋាគារ បាយ៉ន អេវ៉ា ហូថែល ឧបភើរសិន | សៀមរាប |
| 23 | សណ្ឋាគារ អូវៀនថល ជេ7 | សៀមរាប |
| 24 | ក្រុមហ៊ុន ដំរីអង្គរ ខូ អិលធីឌី | សៀមរាប |
| 25 | ក្រុមហ៊ុន បុរី អង្គរ | សៀមរាប |
| 26 | ភោជនីយដ្ឋាន វីវ៉ា | សៀមរាប |
| 27 | ក្រុមហ៊ុន អេប៉ិច ខេមបូឌា ត្រាវ៉ែល សែវីស | សៀមរាប |
| 28 | ក្រុមហ៊ុន ណារ៉ូទូ ឌ្រីម | សៀមរាប |
| 29 | សណ្ឋាគារ អង្គរ | សៀមរាប |
| 30 | ក្រុមហ៊ុន អង្គរ ហូលីដេ | សៀមរាប |
| 31 | ក្រុមហ៊ុន ស៊ីវ៉ាយ-អេសអ ហូថេល ហ្រ្គេន ឡាយអិន ឯ.ក | សៀមរាប |
| 32 | ក្រុមហ៊ុន ផ្លាហ្សា ព្រីមៀ ឡូញ (ខេមបូឌា) សាខាសៀមរាប | សៀមរាប |
| 33 | ក្រុមហ៊ុន អេរីតាស II | សៀមរាប |
| 34 | ផ្ទះសំណាក់ ឌីណាតា អង្គរ | សៀមរាប |
| 35 | ភោជនីយដ្ឋានចាន់រីទ្រី | សៀមរាប |
| 36 | ភោជនីយដ្ឋានសុខៈរីវើ | សៀមរាប |
| 37 | សណ្ឋាគារ ហិមា ប៊ូទិក | សៀមរាប |
| 38 | ក្រុមហ៊ុន ម៉ុនស៊ូន អេស៊ាន ប៊ីស្ត្រូ | សៀមរាប |
| 39 | ក្រុមហ៊ុន ហាប់ ហេង អ៊ិនវេសមេន ភីធីអ៊ី អិលធីឌី | សៀមរាប |
| 40 | សណ្ឋាគារ ស្មាយលីង | សៀមរាប |
| 41 | ក្រុមហ៊ុន ថ្មរូង ឌីវេឡុបមេន | ព្រះសីហនុ |